# សេចក្តីសង្ខេបស្តីពី សន្ធិសញ្ញាស្តីពីការវិនិយោគអន្តរជាតិ និងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ

ខែធ្នូ ឆ្នាំ២០២១

Columbia Center on Sustainable Investment
A JOINT CENTER OF COLUMBIA LAW SCHOOL AND THE EARTH INSTITUTE, COLUMBIA UNIVERSITY

**តើការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) គឺជាអ្វី?** ការវិនិយោគដោយផ្ទាល់ពីបរទេសកើតឡើងនៅពេលរូបវន្តបុគ្គលម្នាក់ ឬសាជីវកម្មក្នុងប្រទេសមួយ (រដ្ឋកំណើត) បង្កើតឡើង ឬទិញផ្នែកទាំងអស់ ឬផ្នែកជាក់លាក់មួយនៃក្រុមហ៊ុនមួយ ដែលមានប្រតិបត្តិការនៅប្រទេសមួយផ្សេងទៀត (រដ្ឋម្ចាស់ផ្ទះ)។ ក្រុមហ៊ុនទាំងឡាយ ដែលវិនិយោគនៅបរទេស ដើម្បីទទួលបានធនធានពីដីធ្លី រួមមាន រ៉ែ, កម្លាំងពលកម្មតម្លៃទាប ដូចជា វិស័យកម្មន្តសាល, និងទីផ្សារថ្មី ក៏ដូចជាមូលហេតុផ្សេងទៀត។ ប្រទេសជាច្រើនស្វែងរកការទាក់ទាញ ការវិនិយោគដោយផ្ទាល់ពីបរទេស ដើម្បីឲ្យដឹងពីអត្ថប្រយោជន៍ មានទម្រង់ជាប្រាក់សារពើពន្ធ, ការផ្ទេរបច្ចេកវិទ្យា, ការបង្កើតការងារ, និងទំនាក់ទំនងផ្នែកសេដ្ឋកិច្ចផ្សេងទៀត។ រូបភាពខាងក្រោមបង្ហាញអំពីគោលគំនិតសំខាន់នៃការវិនិយោគដោយផ្ទាល់ពីបរទេស ក៏ដូចជាវិស័យខ្លះ និងឧស្សាហកម្មដែលទទួលបានការវិនិយោគនេះ។







រដ្ឋាភិបាល, អង្គការអន្តររដ្ឋាភិបាល, និងបណ្តាញផ្សព្វផ្សាយរាយការណ៍អំពីទិន្នន័យការវិនិយោគដោយផ្ទាល់ពីបរទេសប្រចាំឆ្នាំ--រដ្ឋាភិបាលទទួលបានប៉ុន្មាន និងនិន្នាការទូទៅជាដើម។ គួរកត់សម្គាល់ថាមានចំណុចខ្លះមិនច្បាស់លាស់នៅក្នុងទិន្នន័យបែបនេះ។ របាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិឆ្នាំ ២០១៩ បានកត់សម្គាល់ថាស្ទើរតែ ៤០% នៃការវិនិយោគដោយផ្ទាល់ពីបរទេសនៅលើសកលលោក អាចជា "ការវិនិយោគខ្មោច" ឬជាការវិនិយោគលើ "សំបកសាជីវកម្ម" ដោយ "មិនមានមូលដ្ឋាន និងមិនមានទំនាក់ទំនងពិតប្រាកដទៅនឹងសេដ្ឋកិច្ច" ។ វិនិយោគនេះ បានលាបពណ៌ទៅជារូបផ្សេងអំពីលំហូរនៃការវិនិយោគដោយផ្ទាល់ពីបរទេសលើសកលលោក ជាងអ្វីដែលអាចមាននៅក្នុងរបាយការណ៍ភាគច្រើន។

*រូបភាពបង្ហាញនៅក្នុងសេចក្តីសង្ខេបនេះ ត្រូវបានរៀបរៀងឡើងដោយសហការជាមួយអង្គការរូបភាពសិទ្ធិមនុស្ស និងមានសម្រាប់ប្រើប្រាស់ស្ថិតក្រោមអាជ្ញាប័ណ្ណរបស់ Creative Commons លើគេហទំព័រ picturehumanrights.org/isds.*

**តើសន្ធិសញ្ញាស្ដីពីការវិនិយោគអន្តរជាតិគឺជាអ្វី?** សន្ធិសញ្ញានេះ (គេក៏ហៅថាជាកិច្ចព្រមព្រៀងវិនិយោគអន្តរជាតិ ឬ IIAs) គឺជាសន្ធិសញ្ញាទ្វេភាគី ឬពហុភាគី ដែលរដ្ឋជាភាគីប្ដេជ្ញាចិត្តខិតខំប្រឹងប្រែងអនុវត្តបទដ្ឋានជាក់លាក់ចំពោះវិនិយោគិនបរទេសដែលមកពីរដ្ឋភាគីម្ខាងទៀត។ សន្ធិសញ្ញាទាំងនេះផ្ដល់ឲ្យវិនិយោគិនបរទេសនូវការការពារ និងអត្ថប្រយោជន៍ជាក់លាក់ រួមទាំង ជំនួយក្នុងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ កើតឡើងនៅក្នុងរដ្ឋជាម្ចាស់ផ្ទះផងដែរ។ កិច្ចព្រមព្រៀងបែបនេះមានចំនួនជាង ៣.៣០០ ត្រូវបានបញ្ចប់នៅលើពិភពលោក។

តើសន្ធិសញ្ញាការវិនិយោគអន្តរជាតិគឺជាអ្វី ?



រូបភាពបានពីអង្គការសិទ្ធិមនុស្ស
មជ្ឈមណ្ឌល កូឡុំប៊ី ស្ដីពីការវិនិយោគប្រកបដោយចីរភាព

**ហេតុអ្វីបានជាប្រទេសនានាចុះហត្ថលេខាលើសន្ធិសញ្ញាស្ដីពីការវិនិយោគអន្តរជាតិ?** ជារឿយៗ រដ្ឋផ្សេងៗចុះហត្ថលេខាលើសន្ធិសញ្ញាស្ដីពីការវិនិយោគអន្តរជាតិ ដោយផ្អែកលើការសន្មតថា (១) មានការការពារលើការវិនិយោគ និងអភ័យឯកសិទ្ធិដែលនឹងមានការលើកស្ទួយលំហូរនៃការវិនិយោគ, (២) លំហូរនៃការវិនិយោគទាំងនោះនឹងជួយលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចិរភាព, និង (៣) បង្កើតអត្ថប្រយោជន៍មកពីសន្ធិសញ្ញាស្ដីពីការវិនិយោគអន្តរជាតិច្រើនជាងការចំណាយរបស់រដ្ឋ និងប្រជាពលរដ្ឋរបស់ខ្លួន។ អ្នកគាំទ្រសន្ធិសញ្ញាស្ដីពីការវិនិយោគអន្តរជាតិ ក៏បានអះអាងថាសន្ធិសញ្ញាទាំងនេះ រួមទាំងយន្តការដោះស្រាយវិវាទ បានរារាំងវិវាទផ្សេងៗរវាងវិនិយោគិន និងរដ្ឋ និងរវាងរដ្ឋ និងរដ្ឋជាភាគី ឲ្យក្លាយទៅជាមិនមែនរឿងនយោបាយ និងលើកស្ទួយនីតិរដ្ឋ។

ទោះជាយ៉ាងណា ភស្តុតាងតាមបទពិសោធន៍ មិនបានបញ្ជាក់ថាសន្ធិសញ្ញាស្ដីពីការវិនិយោគអន្តរជាតិពិតជាបានជំរុញការវិនិ យោគទុនថ្មីៗនោះទេ កុំថាឡើយបានបង្ហាញថាការវិនិយោគទាំងនោះពិតជាផ្ដល់អត្ថប្រយោជន៍ដល់ប្រទេសដែលជាម្ចាស់ផ្ទះ (ឬប្រទេសកំណើត) ឬថាតើ អត្ថប្រយោជន៍នៃការវិនិយោគថ្មីណាមួយមានច្រើនជាងការចំណាយ ដែលអាចពាក់ព័ន្ធនឹងសន្ធិសញ្ញាស្ដីពីការវិនិយោគនេះ (ដូចជា នៅក្នុងទម្រង់បាត់បង់លំហបទដ្ឋានគតិយុត្ត ការចំណាយលើការការពារវិវាទ និងការចំណាយប្រាក់លើសេវាចេញមជ្ឈត្តវិនិច្ឆ័យផ្សេង)។ ការវិភាគលើលទ្ធផលនៃការសិក្សាជាក់ស្ដែងចំនួន ៧៤ ក្នុងឆ្នាំ ២០២០ បានរកឃើញថាប្រសិទ្ធិភាពនៃសន្ធិសញ្ញាស្ដីពីការ វិនិយោគអន្តរជាតិលើការវិនិយោគដោយផ្ទាល់ពីបរទេសគឺ "មានតិចតួចដែលចាត់ថា ដូចស្មើសូន្យ។"[1]

មានចម្ងល់ស្រដៀងគ្នានេះ អំពីការចូលរួមចំណែករបស់សន្ធិសញ្ញាស្ដីពីការវិនិយោគអន្តរជាតិទៅលើគោលបំណងដែលគេបានអះអាងផ្សេងទៀត ហៅថា ការរារាំងវិវាទមិនឲ្យទៅជារឿងនយោបាយ និងនីតិរដ្ឋទំនើបកម្ម។ ផ្អែកតាម សំណួរជាច្រើនថាតើ សន្ធិសញ្ញាស្ដីពីការវិនិយោគអន្តរជាតិបានរៀបចំឡើង ដើម្បីសម្រេចនូវគោលដៅដែលបានចែងប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផលដែរឬទេ ហើយនិងថាតើគោលដៅទាំងនោះដែលបានចែងស្របគ្នានឹងគោលដៅរបស់ប្រទេសដែរឬទេ និងមានការបារម្ភជាច្រើនអំពីការចំណាយដែលសន្ធិសញ្ញាស្ដីពីការវិនិយោគអន្តរជាតិអាចនឹងដាក់ទៅលើរដ្ឋនានា និងអ្នកពាក់ព័ន្ធទាំងឡាយក្នុងរដ្ឋទាំងនោះ។

[1] ការវិភាគតាមបែបមេតាមួយទៀតនៅឆ្នាំ២០២០ លើការសិក្សាជាក់ស្ដែងចំនួន ៤០ បានប៉ាន់ប្រមាណថាផលប៉ះពាល់នៃសន្ធិសញ្ញា IITs លើកំណើន FDI ជាទូទៅគឺទាបជាង១% យោងតាមឯកសារដែលបោះពុម្ពផ្សាយ។

ខណៈដែលពុំមានភស្តុតាងច្បាស់លាស់បញ្ជាក់ថាសន្ធិសញ្ញាស្តីពីការវិនិយោគអន្តរជាតិ ជំរុញលំហូរវិនិយោគថ្មី អាចមានប្រសិទ្ធិភាពមកពីរបៀបរៀបចំរចនាសម្ព័ន្ធរបស់វិនិយោគ។ នេះដោយសារតែអាជ្ញាកណ្តាលបានបកស្រាយសន្ធិសញ្ញា ដោយអនុញ្ញាតឲ្យវិនិយោគិននាំយកការទាមទារ តាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនទិញភាគហ៊ុនរបស់ខ្លួនដែលមានទីតាំងនៅក្នុងប្រទេសភាគីនៃសន្ធិសញ្ញា។

## ការរៀបចំរចនាសម្ព័ន្ធក្រុមហ៊ុន៖ អ្វីៗសុទ្ធតែអាចទៅរួចដោយច្បាប់




រូបភាពបានពីអង្គការសិទ្ធិមនុស្ស
មជ្ឈមណ្ឌល កូឡុំប៊ី ស្តីពីការវិនិយោគប្រកបដោយចីរភាព

**តើអភ័យឯកសិទ្ធិអ្វីខ្លះដែលសន្ធិសញ្ញាស្តីពីការវិនិយោគអន្តរជាតិផ្តល់ជូនវិនិយោគិន?** សន្ធិសញ្ញាស្តីពីការវិនិយោគអន្តរជាតិ ជាធម្មតាតម្រូវឲ្យរដ្ឋផ្តល់នូវបទដ្ឋានគតិយុត្តនៃការប្រព្រឹត្តិជាក់លាក់លើវិនិយោគិនបរទេស។ បទប្បញ្ញត្តិទាំងនោះរួមមាន៖

- លក្ខខណ្ឌតម្រូវឲ្យសងទៅវិនិយោគិនក្នុងករណីមានការដកហូតយកទ្រព្យសម្បត្តិដោយផ្ទាល់ ឬដោយប្រយោលដោយរដ្ឋ
- ការការពារប្រឆាំងនឹងការប្រព្រឹត្តិពីសំណាក់តួអង្គរដ្ឋាភិបាលដែលសាលាក្តីយល់ថា "មិនយុត្តិធម៌" ឬ "មិនមានសមធម៌" ដែលត្រូវបានគេបកស្រាយដើម្បីគ្របដណ្តប់លើ "ក្តីរំពឹងស្របច្បាប់" របស់វិនិយោគិនអំពីសកម្មភាពអាជីវកម្មនាពេលអនាគត និងទង្វើរបស់រដ្ឋាភិបាល និង
- ការការពារប្រឆាំងនឹង "ការរើសអើង" ដែលត្រូវបានគេបកស្រាយ ដើម្បីបង្ការការប្រព្រឹត្តិពុំសមហេតុផល ទោះបីជាមិនមានការរើសអើងផ្អែកលើជាតិសាសន៍យ៉ាងណាក៏ដោយ។

**តើការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋគឺជាអ្វី?** សន្ធិសញ្ញាស្តីពីការវិនិយោគអន្តរជាតិ អនុញ្ញាតឲ្យវិនិយោគិន (រូបវន្តបុគ្គលឬក្រុមហ៊ុន) ក្នុងការតវ៉ាលើការបំពានលើសន្ធិសញ្ញា ដោយធ្វើការប្តឹងរដ្ឋនានា ទៅអាជ្ញាកណ្តាល។ សាលាក្តីអាជ្ញាកណ្តាលត្រូវបានតែងតាំង និងទទួលប្រាក់សេវាពីភាគីវិវាទម្ខាង ឬទាំងសង្ខាង។ សាលាក្តីនេះមិនភ្ជាប់កាតព្វកិច្ចយុត្តិសាស្ត្រទេ និងអាចចេញបញ្ជាជាសំណងជួសជុល (ជាធម្មតាជាទម្រង់សំណងរូបិយវត្ថុ) ដល់វិនិយោគិន ប្រសិនបើសាលាក្តីយល់ឃើញថា រដ្ឋបានបំពានកាតព្វកិច្ចរបស់ខ្លួនក្រោមសន្ធិសញ្ញាមែន។ ករណីភាគច្រើន វិនិយោគិនមិនតម្រូវឲ្យធ្វើការដោះស្រាយវិវាទ តាមរយៈការផ្តល់

២ ការដកហូតទ្រព្យដោយប្រយោលដែលត្រូវបានកំណត់ថាជាវិធានការមួយនៃវិធានការជាស៊េរីរបស់រដ្ឋាភិបាលដកហូតទ្រព្យដែលមានតម្លៃច្រើនពីការវិនិយោគរបស់វិនិយោគិន។

៣ វិនិយោគិនដែលត្រូវបានការពារ អាចរួមមិនត្រឹមតែសហគ្រាសចម្រុះថ្នាក់ជាតិ (MNE) ដែលមានទីស្នាក់ការនៅក្នុងរដ្ឋជាភាគីនៃសន្ធិសញ្ញានោះទេ ប៉ុន្តែថែមទាំងជាក្រុមហ៊ុនបុត្រសម្ព័ន្ធមួយដែលបានបង្កើតឡើងនៅក្នុងភាគីនៃសន្ធិសញ្ញា បំណុល ឬវិនិយោគិនភាគហ៊ុន អ្នកមានកម្មសិទ្ធិបញ្ញា ភាគីទី៣ជាអ្នកផ្តល់ថវិកាដាក់ទុនវិនិយោគក្នុងក្រុមហ៊ុនដោយសន្មតថាទទួលបានឯកសិទ្ធិលើប្រព័ន្ធ ISDS និងរូបវន្តបុគ្គល និងនិតិបុគ្គលផ្សេងៗទៀត។

សំណងតាមយន្តការដែលមាននៅក្នុងស្រុកទេមុនពេលដាក់ពាក្យតវ៉ាទាមទារទៅកាន់យន្តការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ។ នេះគឺពិសេស និងមិនធម្មតាទេៈ ដែលផ្ទុយពីអង្គការពាណិជ្ជកម្មពិភពលោក ដែលអនុញ្ញាតឲ្យតែរដ្ឋជាភាគីនាំយកការទាមទារទៅរដ្ឋមួយផ្សេងទៀតប៉ុណ្ណោះ ហើយតុលាការសិទ្ធិមនុស្សអន្តរជាតិតម្រូវឲ្យភាគីទាមទារប្តឹងតវ៉ា ដោយប្រើប្រាស់យន្តការទទួលពាក្យបណ្តឹងដោះស្រាយក្នុងស្រុកឲ្យអស់លទ្ធភាពសិន មុននឹងនាំយកវិវាទនេះទៅកាន់កម្រិតលើសពីថ្នាក់ជាតិ។

## តើការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋគឺជាអ្វី?
## ផ្នែកទី ១៖ អំណាច




រូបភាពបានពីអង្គការសិទ្ធិមនុស្ស
មជ្ឈមណ្ឌល កូឡុំប៊ី ស្តីពីការវិនិយោគប្រកបដោយចីរភាព

**តើយន្តការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋជះឥទ្ធិពលលើលទ្ធភាពរបស់រដ្ឋក្នុងការគ្រប់គ្រងយ៉ាងដូចម្តេចខ្លះ?** វិធីម៉្យាងដើម្បីគិតអំពីសន្ធិសញ្ញានោះគឺថា សន្ធិសញ្ញាទាំងនោះផ្តល់នូវការការពារយ៉ាងខ្លាំងដែលអាចអនុវត្តបានជាអន្តរជាតិ ចំពោះសិទ្ធិ និងអត្ថប្រយោជន៍សេដ្ឋកិច្ចរបស់វិនិយោគិនដែលស្ថិតក្រោមសន្ធិសញ្ញានេះ ដែលវាស្រដៀងគ្នាទៅនឹង "បែបបទនៃរបបឡូចណ៍រីសឹម (Lochnerism) នៃតុលាការកំពូលរបស់សហរដ្ឋអាមេរិក រហូតដល់ទសវត្សរ៍ឆ្នាំ ១៩៣០"។ អភិក្រមបែបនេះផ្តល់អភ័យឯកសិទ្ធិផ្នែកសេដ្ឋកិច្ច និងអត្ថប្រយោជន៍ដល់វិនិយោគិនអន្តរជាតិ/សហគ្រាសពហុប្រទេស លើការប្រកួតប្រជែងអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ចរបស់ស្ថាប័ន និងរូបវន្តបុគ្គលផ្សេងទៀត។ (ទោះបីជាយ៉ាងនេះក្តី ភាពខុសគ្នាពីបែបបទរបបឡូចណ៍រីសឹមដែលតុលាការកំពូលសហរដ្ឋអាមេរិកមានលទ្ធភាពផ្លាស់ប្តូរកិច្ចការផ្សេងៗ ជាពិសេសវាជាការលំបាកក្នុងការផ្លាស់ប្តូរឲ្យត្រឹមត្រូវ ដោយនៅពេលដែលច្បាប់ស្តីពីវិនិយោគអន្តរជាតិមានសភាពផ្សេងគ្នា ហើយជារឿយៗមិនត្រូវគ្នា ដែលបណ្តាលមកពីខ្វះការពិនិត្យ និងខ្វះតុល្យភាពសមរម្យ)។ ការប្រព្រឹត្តិខុសគ្នានេះហើយ អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលបានប្រឹងប្រែងរក ការចំណាយលើការរៀបចំលិខិតបទដ្ឋានគតិយុត្តកើនឡើង ដូចដែលអ្នកតំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិកបានទទួលស្គាល់ថា នេះអាចបង្កឲ្យប៉ះពាល់ដល់ទង្វើស្មោះត្រង់ដើម្បីអត្ថប្រយោជន៍សាធារណៈ។

---

៤ សូមមើល, ឧទាហរណ៍, សំណុំរឿង Federal Elektrik Yatirim v. Uzbekistan, ICSID Case លេខ No. ARB/13/9; សំណុំរឿង Quiborax v. Bolivia, ICSID Case លេខ No. ARB/06/2, មជ្ឈត្តវិនិច្ឆ័យចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៥ Award, ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៥។

៥ សូមមើល, ឧទាហរណ៍, សំណុំរឿង Glamis Gold Ltd. v. United States, មជ្ឈត្តវិនិច្ឆ័យចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០០៩, Award; សំណុំរឿង Lone Pine Resources v. Canada, ICSID Case លេខ No. UNCT/15/2 (UNCITRAL); សំណុំរឿង Vattenfall AB, Vattenfall Europe AG, Vattenfall Europe Generation AG v. Germany, ICSID Case លេខ No. ARB/09/6; សំណុំរឿង Gabriel Resources v. Romania, ICSID Case លេខ No. ARB/15/31; សំណុំរឿង CI
សូមមើល, ឧទាហរណ៍, សំណុំរឿង RWE v. the Netherlands, ICSID Case លេខ No. ARB/21/4; សំណុំរឿង Uniper v. the Netherlands, ICSID Case លេខ No. ARB/21/22;

មានករណីមួយចំនួនដែលត្រូវបានដាក់ប្តឹងតវ៉ាទៅរដ្ឋ រួមមានដូចជាៈ

- កិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងការគេចពន្ធ និងការលាងសម្អាតលុយ
- កិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងច្បាប់បរិស្ថាន និងការអនុវត្តច្បាប់នេះ
- កិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងការដាក់កំហិតលើការបូមប្រេងធម្មជាតិ
- លិខិតបទដ្ឋានគតិយុត្តរដ្ឋាភិបាលលើតម្លៃ និងគុណភាពសេវាសាធារណៈជាសារវ័ន្ត ដូចជាការផ្តល់ទឹកស្អាត និងថាមពល
- លិខិតបទដ្ឋានគតិយុត្តរដ្ឋាភិបាលលើផលិតផល និងសេវាកម្មថែទាំសុខភាព
- កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការការពារកម្មសិទ្ធិបញ្ញានៅកម្រិតដែលរក្សាតុល្យភាពរវាងសេចក្តីត្រូវការឯកជន និងសាធារណៈ
- កិច្ចផ្តួចផ្តើមរបស់រដ្ឋាភិបាលក្នុងការព្យាយាមកាត់បន្ថយផលប៉ះពាល់នៃការរើសអើងប្រវត្តិសាស្ត្រ និង
- កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការធានាថាការវិនិយោគបរទេសពិតជាកាតាលីករជំរុញការអភិវឌ្ឍក្នុងស្រុក

**តើការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋជះឥទ្ធិពលលើសិទ្ធិរបស់ភាគីទីបីយ៉ាងដូចម្តេចខ្លះ?** ដំណើរការយន្តការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋជាទូទៅមានភាពពុំច្បាស់លាស់, ជាសម្ងាត់, និងដាច់ដោយឡែក បើប្រៀបធៀបទៅនឹងប្រព័ន្ធច្បាប់របស់សហរដ្ឋអាមេរិក និងច្បាប់ក្នុងស្រុកផ្សេងទៀត ដែលមានតម្លាភាពជាង និងមានយន្តការក្នុងការពិចារណា និងការពារសិទ្ធិ និងអត្ថប្រយោជន៍របស់ជនដែលមិនមែនជាភាគី។ សាលាក្តីដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ មានឆន្ទានុសិទ្ធិក្នុងការទទួល ឬមិនទទួលសេចក្តីថ្លែងការពារផ្លូវច្បាប់ពីភាគីទីបី ប៉ុន្តែជាញឹកញយ យន្តការនេះបដិសេធ (សូមចូលមើល here និង here) ឬមានការដាក់កំរិតជាក់លាក់លើភាគីទីបី ទោះបីជាសិទ្ធិ ឬអត្ថប្រយោជន៍របស់ជនមិនមែនជាភាគី រងផលប៉ះពាល់ដោយផ្ទាល់នៅក្នុងការទាមទារនៅក្នុងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋយ៉ាងណាក្តី។ ខុសពីការការពារផ្នែកច្បាប់ទូទៅ ជនមិនមែនជាភាគីដែលរងផលប៉ះពាល់នោះអាចចូលរួមក្នុងសំណុំរឿងបាន (ដូចជាភាគីឆ្លើយតប ឬអ្នកពាក់ព័ន្ធនឹងភាគីប្តឹងទាមទារ) និង/ឬតម្រូវឲ្យមានការប្រានចោលការទាមទារ ប្រសិនបើភាគីទីបី ដែលរងផលប៉ះពាល់មិនអាចចូលរួមក្នុងនីតិវិធីបាន, ភាគីទីបីដែលរងផលប៉ះពាល់នៅក្នុងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ មិនមានលទ្ធភាពច្បាស់លាស់ក្នុងការធ្វើអន្តរាគមន៍នៅក្នុងដំណើរការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព, និងមិនមានវិធានផ្តល់ឲ្យការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋត្រូវប្រានចោលនៅពេលសំណុំរឿងទាំងនោះគំរាមកំហែងដល់សិទ្ធិរបស់ភាគីទីបី។

---

៦ សំណុំរឿង Rockhopper v. Italy, ICSID Case លេខ No. ARB/17/14; សំណុំរឿង TransCanada v. USA, ICSID Case លេខ No. ARB/16/21; សំណុំរឿង Westmoreland v. Canada, ICSID Case លេខ No. UNCT/20/3; សំណុំរឿង Lone Pine v. Canada, ICSID Case លេខ No. UNCT/15/2.

៧ សូមមើល, ឧទាហរណ៍, សំណុំរឿង United Utilities (Tallinn) B.V. and Aktsiaselts Tallinna Vesi v. Estonia, ICSID Case លេខ No. ARB/14/24; សំណុំរឿង Suez, Sociedad General de Aguas de Barcelona, S.A. and Vivendi Universal, S.A. v. Argentina, ICSID Case លេខ No. ARB/03/19, មជ្ឈត្តវិនិច្ឆ័យចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥ Award, 9 April 2015; សំណុំរឿង TECO Guatemala Holdings, LLC v. Guatemala, ICSID Case No. ARB

៨ សូមចូលអាន Achmea B.V. v. The Slovak Republic, PCA Case No. 2013-12 (UNCITRAL); HICEE B.V. v. The Slovak Republic, PCA Case No. 2009-11 (UNCITRAL), Final Award, 17 October 2011; Apotex Holdings Inc. and Apotex Inc. v. United States of America, ICSID Case No. ARB/AF/12/1, Award, 25 August 2014.

រដ្ឋាភិបាលនានា ថ្មីៗនេះបានបញ្ជាក់ថា កិច្ចខិតខំប្រឹងប្រែងកំណែទម្រង់ជាអន្តរជាតិ គួរដោះស្រាយក្តីកង្វល់ដែលថា សិទ្ធិ ឬអត្ថប្រយោជន៍របស់ភាគីទីបីអាចរងផលប៉ះពាល់ ដោយយន្តការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ។ ប៉ុន្តែនៅពុំទាន់មានផែនការច្បាស់លាស់ក្នុងការអនុវត្ត ឬជំរុញកំណែទម្រង់ទាំងនោះឡើយ។



រូបភាពបានពីអង្គការសិទ្ធិមនុស្ស
មជ្ឈមណ្ឌល កូឡុំប៊ី ស្តីពីការវិនិយោគប្រកបដោយចីរភាព

**តើធ្លាប់មានសំណុំរឿងប៉ុន្មាន?** រហូតដល់ចុងឆ្នាំ ២០១៨ យ៉ាងហោចណាស់ក៏មានសំណុំរឿងចំនួន ១១០៤ បានដាក់ប្តឹង។ ចំនួនសំណុំរឿងបានកើនឡើងយ៉ាងឆាប់រហ័សក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ខណៈដែលករណីវិវាទដំបូងបំផុតគឺមាននៅក្នុងឆ្នាំ ១៩៨៧ ហើយដែលជាងពាក់កណ្តាលនៃសំណុំរឿងទាំងអស់រហូតមកដល់បច្ចុប្បន្ន គឺបានដាក់ប្តឹងនៅចន្លោះឆ្នាំ ២០១៣ និង ២០២១។

**តើជាធម្មតានរណាជាអ្នកនាំវិវាទរវាងវិនិយោគិន និងរដ្ឋប្តឹងទៅរកការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ? ហើយជាធម្មតាភាគីណាជាភាគីឆ្លើយតប?** សំណាងទាមទារដែលជោគជ័យគឺ ជារឿយៗនាំយកបណ្តឹងដោយសាជីវកម្មពហុប្រទេសច្រើន៖ ក្រុមហ៊ុនដែលមានចំណូលប្រចាំឆ្នាំជាងមួយពាន់លានដុល្លារអាមេរិក និងរូបវន្តបុគ្គលដែលមានទ្រព្យលើសពីមួយរយលានដុល្លារអាមេរិក ធ្លាប់ទទួលបានមជ្ឈត្តវិនិច្ឆ័យដោយផ្នែក ឲ្យផ្ទេរហិរញ្ញវត្ថុក្នុងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ ប្រមាណ ៩៤,៥% (៩៣,៥% ប្រសិនបើមានការដាក់បញ្ចូលទាំងកាប្រាក់ មុននឹងចេញមជ្ឈត្តវិនិច្ឆ័យ)។ វិនិយោគិនដែលជាភាគីប្តឹងទាមទារភាគច្រើនលើសលុប (៨៦%) គឺមកពីបណ្តាប្រទេសមានចំណូលខ្ពស់ ហើយសំណុំរឿងភាគច្រើន (៦៦%) គឺជាបណ្តឹងតទល់នឹងបណ្តាប្រទេសដែលមានចំណូលទាប និងមធ្យម។ ជាពិសេស ក្នុងបណ្តាប្រទេសដែលមានចំណូលទាប ការចាញ់ក្តីក្នុងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ អាចជះឥទ្ធិពលលើសេដ្ឋកិច្ចយ៉ាងខ្លាំង (សូមមើល here និង here)។

៩ សូមមើល, ឧទាហរណ៍, សំណុំរឿង Eli Lilly and Company v. Canada, ICSID Case លេខ No. UNCT/14/2 (UNCITRAL), មជ្ឈត្តវិនិច្ឆ័យស្ថាពរ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧។

១០ សូមមើល, ឧទាហរណ៍, សំណុំរឿង Piero Foresti, Laura de Carli & Others v. South Africa, ICSID Case លេខ No. ARB(AF)/07/1, មជ្ឈត្តវិនិច្ឆ័យ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០។

១១ សូមមើល, ឧទាហរណ៍, សំណុំរឿង Mobil Investments Canada Inc. and Murphy Oil Corporation v. Canada, ICSID Case លេខ No. ARB(AF)/07/4.

១២ ទោះជាយ៉ាងណាក៏ដោយមិនមែនគ្រប់សំណុំរឿង ឬពាក្យបណ្តឹងទាំងអស់សុទ្ធតែជាសាធារណៈទេពីព្រោះវិធានទាំងឡាយដែលតម្រូវឲ្យមានតម្លាភាពមិនត្រូវបានអនុម័ត ឬអនុវត្តដូចគ្នានោះទេ។ ភាគីវិវាទ និង/ឬមជ្ឈត្តករនៅតែអាចធ្វើសេចក្តីសម្រេច ដោយព្យាយាមរក្សាអាជ្ញាកណ្តាលដោយផ្នែក ឬទាំងស្រុងជាការសម្ងាត់ ទោះបីជាក្នុងករណីបែបនេះ អ្នកសារព័ត៌មាន និងអ្នកដទៃទៀតអាចព្យាយាមប្រើសេរីភាពនៃច្បាប់ស្តីពីសារព័ត៌មាន ដើម្បីព្យាយាមទទួលបានព័ត៌មានដែលពាក់ព័ន្ធ

**តើនរណាជាអ្នកធ្វើសម្រេចលើសំណុំរឿង?** ជាធម្មតារឿងវិវាទនៅក្នុងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ ធ្វើសេចក្ដីសម្រេចដោយអាជ្ញាកណ្ដាលចំនួន ៣ រូប ដែលតែងតាំង និងចំណាយដោយវិនិយោគិន និងតែងតាំងដោយរដ្ឋដែលពាក់ព័ន្ធ (ជាធម្មតាអាជ្ញាកណ្ដាល១រូប ជ្រើសរើសដោយភាគីនីមួយៗ ហើយម្នាក់ទៀតជ្រើសរើសរួមគ្នា)។ ការជ្រើសរើសអាជ្ញាកណ្ដាល ជាទូទៅមិនស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវការលើគុណវុឌ្ឍិអ្វីឡើយ (ដូចជា មិនពាក់ព័ន្ធនឹងជំនាញឯកទេសជាដើម) ហើយក៏មិនមានការធានាអំពីឯករាជ្យភាពឲ្យបានល្អប្រសើរឡើយ។ មានក្រុមអាជ្ញាកណ្ដាលចំនួនតូចមួយដែលត្រូវបានតែងតាំង និងត្រូវតែងតាំងឡើងវិញក្នុងសំណុំរឿងភាគច្រើនលើសលុប។ អាជ្ញាកណ្ដាលមួយចំនួនក៏ "ពាក់មួកពីរ" ដោយតំណាងឲ្យភាគីប្ដឹងទាមទារក្នុងសំណុំរឿងវិវាទផង ក្នុងខណៈដែលខ្លួនដែលជាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងផ្សេងទៀតផង។ នេះអាច និងធ្លាប់នាំឲ្យមានសេណារីយ៉ូ ដែលមេធាវីបានប្រើប្រាស់មជ្ឈត្តវិនិច្ឆ័យដែលខ្លួនជាអាជ្ញាកណ្ដាល ដើម្បីគាំទ្រគោលជំហផ្លូវច្បាប់របស់ពួកគេក្នុងពេលដដែលតវ៉ានៅក្នុងសំណុំរឿងផ្សេងជាមេធាវីតំណាងដោយអាណត្តរបស់ភាគី។ លើសពីនេះ មេធាវី និងអាជ្ញាកណ្ដាលខ្លះ ទទួលបានប្រាក់សេវាជាអ្នកជំនាញការនៅក្នុងរឿងវិវាទផ្សេងទៀត ឬជាទីប្រឹក្សាឲ្យម្ចាស់មូលនិធិភាគីទីបីនៅក្នុងការទាមទារសំណងផងដែរ។ (ដូចមានការកត់សម្គាល់ខាងក្រោម បច្ចុប្បន្ននេះសហភាពអឺរ៉ុបកំពុងតែឈានមុខគេក្នុងការព្យាយាមជំនួសអាជ្ញាកណ្ដាលដែលតែងតាំង និងទទួលប្រាក់សេវាពីភាគី មកពីស្ថាប័នល្បីឈ្មោះ ឬជាក្រុមអាជ្ញាកណ្ដាលនៅក្នុងបញ្ជី។ ថ្មីៗនេះ ក៏មានកិច្ចខិតខំប្រឹងប្រែងខ្លះទៀតក្នុងការកាត់បន្ថយ "ការពាក់មួកពីរ" នៅក្នុងសន្ធិសញ្ញា ដែលកំពុងតែមានការចរចា និងតាមរយៈដំណើរការកំណែទម្រង់ការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋដែលកំពុងតែអនុវត្ត នៅគណៈកម្មការអង្គការសហប្រជាជាតិស្ដីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ។ ទោះជាយ៉ាងណា ខ្លឹមសារ និងលទ្ធផលនៃកំណែទម្រង់ទាំងនោះនៅតែមានភាពមិនប្រាកដប្រជានៅឡើយ។




**តើអាជ្ញាកណ្ដាលពិចារណាលើអ្វីខ្លះ ដើម្បីធ្វើសេចក្ដីសម្រេចនៅក្នុងសំណុំរឿង?** ទី១ និងជំបូងបំផុត បទប្បញ្ញត្តិពាក់ព័ន្ធរបស់សន្ធិសញ្ញាក្នុងការធ្វើសេចក្ដីសម្រេចនៅក្នុងសំណុំរឿងនានា ថាតើទង្វើសកម្ម (ឬទង្វើអកម្ម) របស់រដ្ឋាភិបាលដែលត្រូវបានជជែកតវ៉ាមាន សង្គតិភាពទៅនឹងច្បាប់ក្នុងស្រុក ឬវិស័យផ្សេងទៀតនៃច្បាប់អន្តរជាតិ (ដូចជាអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ និងក្របខណ្ឌសិទ្ធិមនុស្សជាដើម) ជាទូទៅមិនត្រូវបានយកមកពិចារណាធ្វើជាការការពារទៅនឹងបណ្ដឹងទាមទារ ឬជាការទទួលខុសត្រូវក្រោមសន្ធិសញ្ញាវិនិយោគអន្តរជាតិឡើយ (ប៉ុន្តែជាការបំពានលើប្រភពច្បាប់ផ្សេងៗទៀតអាចជាការបំពានលើសន្ធិសញ្ញាវិនិយោគអន្តរជាតិ)។ ផ្ទុយទៅវិញ ដោយសារសន្ធិសញ្ញា ដែលស្ទើរតែទូទាំងសកលលោក ដាក់កាតព្វកិច្ចដែលអាចអនុវត្តបានតែទៅលើរដ្ឋ មិនមែនលើវិនិយោគិន នោះមានន័យថាជាទូទៅ រដ្ឋអាចមិនផ្ដួចផ្ដើមបណ្ដឹងទាមទារមុន ឬមិនដាក់បណ្ដឹងតប នៅក្នុងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋឡើយ វិនិយោគិនអាចឈ្នះរឿងក្ដី បើទោះបីជាខ្លួនបានបំពានលើច្បាប់ក្នុងស្រុក ឬបទដ្ឋានសិទ្ធិមនុស្ស ឬបទដ្ឋានបរិស្ថានពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ខ្លួន

ក្នុងការវិនិយោគក៏ដោយ។ ដើម្បីមានឥទ្ធិពលលើការបកស្រាយសន្ធិសញ្ញានេះ រដ្ឋការពារខ្លួនឯង ក៏ដូចជាការពារភាគីរដ្ឋផ្សេងទៀត ឬភាគីហត្ថលេខីនៃសន្ធិសញ្ញា (រួមទាំងរដ្ឋកំណើតរបស់វិនិយោគិនផងដែរ) រដ្ឋអាចផ្តល់ ការបកស្រាយបទប្បញ្ញត្តិសន្ធិសញ្ញារួមគ្នា (និងជាទ្វេភាគី) ដើម្បីបញ្ជាក់នូវអ្វីខ្លះដែលបទប្បញ្ញត្តិនៅក្នុងសន្ធិសញ្ញានោះមានអត្ថន័យ។ ប៉ុន្តែ អ្វីដែលរដ្ឋជាភាគីឆ្លើយតបថ្លែងអំពីអត្ថន័យរបស់សន្ធិសញ្ញា គឺជារឿយៗត្រូវបានបដិសេធដោយសាលាក្តីអាជ្ញាកណ្តាល។ ពិតណាស់ ទោះបីជានៅពេលដែលភាគីសន្ធិសញ្ញាទាំងអស់យល់ស្របលើការបកស្រាយសមហេតុផលណាមួយនៃសន្ធិសញ្ញាយ៉ាងណាក៏ដោយ ក៏សាលាក្តីអាចបកស្រាយផ្សេងទៅតាមអ្វីដែលខ្លួនចង់បាន។ សាលាក្តីអាច ហើយនិងតែងតែធ្វើ គឺការទាញ ឬយោងលើមជ្ឈត្តវិនិច្ឆ័យសំណុំរឿងដោះស្រាយវិវាទមុនៗនៅក្នុងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ ប៉ុន្តែមជ្ឈត្តវិនិច្ឆ័យទាំងនោះពុំមានការចងកាតព្វកិច្ចយុត្តិសាស្ត្រឡើយ។




**តើមានអ្វីកើតឡើងនៅពេលវិនិយោគិនឈ្នះក្តី?** ជាទូទៅ សាលាក្តីដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ ពុំមានអាណត្តិបំពេញលទ្ធផលការងារជាក់លាក់អ្វីឡើយ នោះគឺថា អាជ្ញាកណ្តាលមិនកែប្រែ ឬតម្រូវឲ្យមានការអនុវត្តឡើងវិញនូវទង្វើរបស់រដ្ឋឡើយ។ ផ្ទុយទៅវិញ ជាធម្មតាអាជ្ញាកណ្តាលចេញមជ្ឈត្តវិនិច្ឆ័យលើសំណងរូបិយវត្ថុដល់វិនិយោគិន (ទោះបីជាក្នុងករណីដែលសំណងរូបិយវត្ថុពុំអាចអនុវត្តបាននៅក្នុងច្បាប់រដ្ឋយ៉ាងណាក៏ដោយ ដូចជាករណីមានទោសទណ្ឌ ឬអាចមានដំណោះស្រាយផ្សេងទៀតដែលអនុវត្តបាន)។ ប៉ុន្តែ ខ្សែបន្ទាត់រវាងដំណោះស្រាយជាក់លាក់ និងសំណងរូបិយវត្ថុបានក្លាយទៅជាកាន់តែស្រពិចស្រពិលឡើង។ ជាក់ស្តែង សាលាក្តីបានចេញបញ្ជារក្សាការពារទាមទារសំណងពីរដ្ឋ (ដូចជា ការប្រាប់ឲ្យក្រុមហ៊ុនអនុវត្តផ្អាកការបង់ពន្ធ, បញ្ឈប់នីតិវិធីព្រហ្មទណ្ឌ, រារាំងដល់ការអនុវត្តសាលដីកាតុលាការក្នុងស្រុក) ហើយបន្ទាប់មកបានរកឃើញថា រដ្ឋាភិបាលសម្រេចមិនអនុវត្តតាមបញ្ជាទាំងឡាយរបស់សាលាក្តី (ឧ. សូមចូលអាន here)។ មជ្ឈត្តវិនិច្ឆ័យទៅរដ្ឋ ជាធម្មតាកើនឡើងពីរាប់រយលានដុល្លារអាមេរិករហូត ឈានដល់រាប់ពាន់លានដុល្លារអាមេរិក។ គិតត្រឹមខែមិថុនា ឆ្នាំ២០២១ នេះ ចំនួនជាមធ្យមដែលវិនិយោគិនបានប្តឹងទាមទារនៅក្នុងបណ្តឹងទាមទារក្នុងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ គឺចំនួន ១,១៦ ពាន់លានដុល្លារអាមេរិក។ ចំនួនប្រាក់ជាមធ្យមដែលបានបញ្ជាឲ្យសងគឺចំនួន ៤៣៧,៥ លានដុល្លារអាមេរិក។ ការសិក្សាដែលក្នុងឆ្នាំ ២០២១ ក៏បានរកឃើញថា បើសិនជាដកសំណងទាមទារពីរុស្ស៊ីចេញ ទាំងចំនួនមធ្យមដែលបានទាមទារ និងចំនួនមធ្យមដែលបានចេញមជ្ឈត្តវិនិច្ឆ័យ សុទ្ធតែមានការកើនឡើង។ ពិតណាស់ រវាងឆ្នាំ ២០១៧ និង ២០២០ នេះ សាលាក្តីអាជ្ញាកណ្តាលបានចេញមជ្ឈត្តវិនិច្ឆ័យឲ្យរដ្ឋាភិបាលបង់ប្រាក់សងជាមធ្យមចំនួន ៣១៥,៥ លានដុល្លារអាមេរិករាល់ពេលដែលវិនិយោគិនឈ្នះក្តីម្តងៗ។

១៣ ការដកចេញនូវសំណុំរឿងទាមទារធំៗ ជាពិសេសរឿងប្រឆាំងនឹងប្រទេសរុស្ស៊ីសម្រាប់ចំនួនទឹកប្រាក់ដប់ពាន់លានដុល្លារអាមេរិក ជាមធ្យមចំនួនទឹកប្រាក់ដែលទាមទារនៅក្នុងករណីនីមួយៗ គឺ ៨១៧,៣ លានដុល្លារអាមេរិក។

១៤ ការដកចេញនូវមជ្ឈត្តវិនិច្ឆ័យ ទៅលើប្រទេសរុស្ស៊ី ដែលទាមទារដោយវិនិយោគិនធំៗនៅខាងក្រៅ ឱ្យរដ្ឋាភិបាលទូទាត់ប្រាក់ចំនួន ៥០ ពាន់លានដុល្លារអាមេរិកទៅឲ្យវិនិយោគិនជាភាគីទាមទារដោយ ISDS ចេញមជ្ឈត្តវិនិច្ឆ័យដែលមានចំនួនជាមធ្យមគឺ ១៦៩,៥ លានដុល្លារអាមេរិក។




បណ្ដាប្រទេសដែលមានចំណូលទាប និងមធ្យម តែងតែជាកម្មវត្ថុនៃការចេញមជ្ឈត្តវិនិច្ឆ័យឲ្យសង ដែលមានចំនួនធំ ដែលចេញពីថវិកាប្រចាំឆ្នាំរបស់ខ្លួន (ដូចជាធនធានថវិកាដែលអាចយកទៅចំណាយលើវិស័យសុខាភិបាល, អប់រំ, និងអាទិភាពរបស់ជាតិផ្សេងទៀត)

តារាងខាងក្រោមនេះបង្ហាញអំពីតម្លៃនៃមជ្ឈត្តវិនិច្ឆ័យដែលចេញឲ្យរដ្ឋជាភាគីឆ្លើយតបចំនួន ១០ សងក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ធៀបទៅនឹងភាគរយនៃ ផ.ស.ស និងបានបង្ហាញចំនួនប្រាក់នៃមជ្ឈត្តវិនិច្ឆ័យសងទាំងនោះ ធៀបទៅនឹងការចំណាយផ្សេងៗរបស់រដ្ឋនៅអឺរ៉ុប (ជាភាគរយនៃ ផ.ស.ស) លើកម្មវិធីសាធារណៈដទៃទៀត។




ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យបានមកពី UNCTADs ISDS Navigator និង data.europa.eu
គិតត្រឹមថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០២១

១៥ ជាក់ស្ដែង បន្ទាប់ពីប្រទេសអាហ្សង់ទីនខកខានពុំបានគោរពទៅតាមដីកាមួយចំនួនដែលចេញដោយវិនិយោគិនសហរដ្ឋអាមេរិក ក្នុងរវាងឆ្នាំ ២០០០ និង ២០០៨ មក រដ្ឋាភិបាលអាមេរិកបានដកអត្ថ

១៦ ប្រយោជន៍ពាណិជ្ជកម្មដែលអនុញ្ញាតឲ្យអាហ្សង់ទីនក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍទទួលផល ចេញពីប្រព័ន្ធអនុគ្រោះពន្ធ ហើយបានបោះឆ្នោតមិនឲ្យមានការពង្រីកការផ្ដល់កម្ចីដល់ប្រទេសនេះពីសំណាក់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍអន្តរអាមេរិក។ Emmanuel Gaillard, Ilija Mitrev Penushliski, 'State Compliance with Investment Awards,' (2021) ICSID Review – Foreign Investment Law Journal.

១៧ Tethyan Copper Company v. Pakistan, ICSID Case No. ARB/12/1, Final Award, 12 July 2019.

មជ្ឈត្តវិនិច្ឆ័យឲ្យសងមានការអនុវត្តខ្ពស់ និងមិនអាចប្តឹងឧទ្ធរណ៍បាន ទោះបីជាសាលាក្តីដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ មានកំហុសក្នុងការបកស្រាយ ឬអនុវត្តច្បាប់ ឬយល់ដឹងពីអង្គហេតុយ៉ាងណាក៏ដោយ។ ប្រសិនបើរដ្ឋមិនបានបង់ប្រាក់សំណងទៅតាមមជ្ឈត្តវិនិច្ឆ័យ និងវិនិយោគិនជួបប្រទះផលលំបាកក្នុងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ តាមរយៈ ដូចជា ការរឹបអូសទ្រព្យសកម្មរបស់រដ្ឋាភិបាល វិនិយោគិនអាចនឹងព្យាយាមឲ្យរដ្ឋ "ម្ចាស់ផ្ទះ" របស់ខ្លួនដាក់សម្ពាធការទូត ឬដាក់ទណ្ឌកម្មលើរដ្ឋាភិបាលម្ចាស់ផ្ទះ។

**តើមានការចំណាយអ្វីខ្លះចំពោះរដ្ឋជាភាគីឆ្លើយតបទៅនឹងបណ្តឹងទាមទារទាំងនេះ?** ការចំណាយលើដំណើរដោះស្រាយវិវាទនៅការដោះស្រាយវិវាទវិនិយោគិន និងរដ្ឋ ជាមធ្យម គឺប្រមាណ ១៣ លានដុល្លារអាមេរិក សម្រាប់ការចំណាយទាំងភាគីប្តឹងទាមទារ និងភាគីឆ្លើយតប រួមទាំងការចំណាយលើសាលាក្តីផងដែរ។ សំណុំរឿងដែលស្មុគស្មាញ និងមានចំនួនទឹកប្រាក់ធំអាចចំណាយកាន់តែច្រើន។ ឧទាហរណ៍ នៅក្នុងបណ្តឹងទាមទាររវាងក្រុមហ៊ុន ធីស៊ីស៊ី ប្រទេសប៉ាគីស្ថាន ឧទាហរណ៍ ប្រទេសប៉ាគីស្ថានបានចំណាយសេវាផ្លូវច្បាប់ជិត ២៥,៥ លានដុល្លារអាមេរិក។ ត្រូវបានបង្គាប់ឲ្យបង់ប្រាក់សំណងជាង ៥៩,៥ លានដុល្លារអាមេរិក ជាសំណងលើការចំណាយសេវាផ្លូវច្បាប់ដែលបានចំណាយដោយក្រុមហ៊ុនភាគីប្តឹងទាមទារ ក៏ជាការចំណាយទាំងស្រុងលើថ្លៃសេវាអាជ្ញាកណ្តាលជាង ៣,៧ លានដុល្លារអាមេរិក។ សម្រាប់រដ្ឋជាច្រើនដែលជាភាគីឆ្លើយតប នៅក្នុងរយៈពេលខ្លី ថ្លៃសេវាទាំងនេះអាចបន្ថែមកាន់តែច្រើន -- សូមពិចារណាសំណុំរឿងប្រទេសកូឡុំប៊ីដែលមាន ១៧ សំណុំរឿង (និងរាប់) បានដាក់បណ្តឹង ចាប់តាំងពីឆ្នាំ ២០១៦ មក។

**តើ "ភាគីទីបីផ្តល់ថវិកា" លើអ្វីខ្លះ?** តើហេតុអ្វីវាមានសារៈសំខាន់? ក្រុមហ៊ុនហិរញ្ញវត្ថុផ្តល់ថវិកាកាន់តែច្រើន និងជ្រើសរើសវិនិយោគិនឲ្យដាក់បណ្តឹងទាមទារសំណងទៅការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ ដោយចេញការចំណាយផ្លូវច្បាប់របស់ភាគីប្តឹងទាមទារ ដើម្បីទទួលបានមកវិញនូវមជ្ឈត្តវិនិច្ឆ័យលើសំណងដ៏ច្រើនលើសលប់ជាសក្តានុពល។ នេះបង្កើតឲ្យមានលើកជាសំណួរជាច្រើន រួមទាំង ថាតើការអនុញ្ញាតឲ្យមានការណែនាំភាគីទីបីដែលផ្តល់ថវិកា ជំរុញឲ្យមានការកើនឡើងនៃចំនួនបណ្តឹងទាមទារ ឬចំនួនប្រាក់សំណងទាមទារ, ការកើនឡើងនៃការទាមទារប្រាក់សំណង "ដែលលើសលប់", ការផ្លាស់ប្តូរផលធៀបនៃការឈ្នះ និងចាញ់, ផលជះលើលទ្ធផលផ្លូវច្បាប់ និងការអភិវឌ្ឍទូទៅនៃច្បាប់, និងមានផលប៉ះពាល់ទូលំទូលាយជាងមុនលើលំហូរមូលធនអន្តរជាតិ និងពន្ធលើមូលធននោះដែរឬទេ។ ភាគីទីបីដែលផ្តល់ថវិកា នៅក្នុងបណ្តឹងទាមទារប្រាក់សំណងពីរដ្ឋាភិបាល បច្ចុប្បន្នគឺស្ទើរតែពុំមានលិខិតបទដ្ឋានគតិយុត្តណាទាំងអស់នៅក្នុងអាជ្ញាកណ្តាលវិនិយោគ។ នេះផ្ទុយពីអភិក្រមដែលបានអនុវត្តយ៉ាងហោចណាស់ក្នុងប្រទេសមួយចំនួននៅកម្រិតប្រទេស ដែលមានគោលនយោបាយពិចារណាលើការដាក់កំរិតលើការប្រើប្រាស់ថវិកាពីភាគីទីបី ក្នុងសំណុំរឿងទាមទារទៅរដ្ឋាភិបាល។ នៅសហរដ្ឋអាមេរិក ឧទាហរណ៍ គេមានច្បាប់ប្រឆាំងនឹងការតែងតាំងបណ្តឹងទាមទារសំណង ដែលហាមឃាត់ "ការផ្ទេរ ឬការតែងតាំងផ្នែកណាមួយនៃបណ្តឹងទាមទារសំណងទៅរដ្ឋាភិបាលសហរដ្ឋអាមេរិក ឬទទួលបានអត្ថប្រយោជន៍ពីបណ្តឹងទាមទារសំណង" និង"អំណាចក្នុងការទទួលការទូទាត់ប្រាក់ពីផ្នែកណាមួយនៃបណ្តឹងទាមទារ"។ មានការលើកលែងខ្លះ ដូចជា អនុញ្ញាតឲ្យផ្ទេរកាប្រាក់ជូន បន្ទាប់ពី បណ្តឹងទាមទារសំណងទាំងនោះត្រូវបានគេកំណត់ថាត្រឹមត្រូវ និង បន្ទាប់ពី មានមជ្ឈត្តវិនិច្ឆ័យលើចំនួនប្រាក់ដែលជំពាក់។

ការប្រឆាំងនឹងការតែងតាំង ក្នុងគោលបំណងសម្រេចគោលដៅគោលនយោបាយជាច្រើន៖

ទី១, ដើម្បីទប់ស្កាត់ជនដែលមានឥទ្ធិពលមិនឲ្យទិញបណ្តឹងទាមទារ ដែលអាចដាក់សម្ពាធលើមន្ត្រីរដ្ឋាភិបាលដោយមិនត្រឹមត្រូវ។ ទី២, ដើម្បីទប់ស្កាត់ការបង់ប្រាក់លើការទាមទារសំណងច្រើនដែលអាចកើតមាន និងបញ្ចៀសការស៊ើបអង្កេតលើការតែងតាំងមិនត្រឹមត្រូវ ហើយអនុញ្ញាតឲ្យរដ្ឋាភិបាលធ្វើការតែជាមួយភាគីប្តឹងទាមទារដើមតែប៉ុណ្ណោះ និងទី៣, ដើម្បីទុកឲ្យរដ្ឋាភិបាលការពារខ្លួន និងប្តឹងតប ដែលអាចមិនមានអ្នកតែងតាំង។

គោលដៅនៃគោលនយោបាយទាំងនោះ មិនទទួលបានការការពារសិទ្ធិក្រោមអភិក្រមសេរីភាពក្នុងវិស័យឯកជន (Laissez-faire) បច្ចុប្បន្ន ចំពោះភាគីទីបីដែលផ្តល់ថវិកានៅក្នុងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋទេ។

---

១៧ 31 USC § 3727

១៨ Kingsbury v. United States [1977] 563 F.2d 1019, 1024.




**តើបច្ចុប្បន្នយ៉ាងដូចម្តេច? អភិក្រមចំពោះកំណែទម្រង់៖** រដ្ឋមួយចំនួនកំពុងតែពិចារណាលើកំណែទម្រង់ការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ និងទម្រង់គំរូសន្ធិសញ្ញាវិនិយោគអន្តរជាតិថ្មី និងកំពុងតែតាក់តែងសន្ធិសញ្ញាថ្មីដែលមានគោលបំណងយ៉ាងហោចណាស់ដោះស្រាយបញ្ហាដែលធ្លាប់ជួបប្រទះ។ អ្វីដែលសំខាន់គឺថា ក្រុមការងារទី៣ នៃគណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) -- ដែលជាការចរចាស្តីការវិនិយោគរវាងពហុភាគីសំខាន់ដំបូងបំផុត និង ចាប់តាំងពីបរាជ័យរបស់អង្គការដើម្បីសហប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច (OECD) នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ ដើម្បីបង្កើតកិច្ចព្រមព្រៀងពហុភាគីស្តីពីការវិនិយោគ -- ក៏កំពុងតែអនុវត្តកំណែទម្រង់ការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋផងដែរ។

កិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) រួមមានយ៉ាងហោចការបន្តធ្វើការងារខ្លះលើ សំណើឲ្យមានតុលាការវិនិយោគពហុភាគីរបស់សហភាពអឺរ៉ុប ដែលស្នើឲ្យប្តូរការតែងតាំង និងការបង់ប្រាក់សេវាទៅអាជ្ញាកណ្តាលជំនួសដោយ "ចៅក្រម" ដែលទទួលប្រាក់ខែអចិន្ត្រៃយ៍វិញ ដើម្បីជាមធ្យោបាយដោះស្រាយបញ្ហាមួយចំនួននៃយន្តការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋដែលកំពុងមាន។ ទោះជាយ៉ាងណា នេះនឹងមិនធានាថាអាចដោះស្រាយបញ្ហាយន្តការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋដែលបានលើកឡើងដ៏ច្រើនដោយខ្លួនឯងបានឡើយ ដូចជាពាក់ព័ន្ធនឹងវិសាលភាព និងបញ្ហាបទដ្ឋានគតិយុត្តដែលអាចកើតមានឡើងចំពោះសន្ធិសញ្ញាវិនិយោគអន្តរជាតិ។ ពិតណាស់ វាអាចនឹងរាំងស្ទះនឹងការបកស្រាយច្បាប់ និងប្រភេទមជ្ឈត្តវិនិច្ឆ័យសំណងទាមទារលើការខូចខាត ដែលគំរាមកំហែងចំពោះការរារាំងដោយគ្មានកាលកំណត់ ឬការបង្កើនការចំណាយលើលិខិតបទដ្ឋាគតិយុត្តពីអត្ថប្រយោជន៍របស់រដ្ឋ ឬប្តូរការចំណាយទាំងនោះទៅជាការចំណាយសាធារណៈដែលមិនត្រូវគ្នានឹងគោលការណ៍ "អ្នកបំពុលបរិស្ថានបង់ប្រាក់" ឬការពិចារណាយ៉ាងសមធម៌ផ្សេងទៀត។ វាក៏មានភាពពុំច្បាស់លាស់ដែរថាតើ សំណើឲ្យមានតុលាការពហុភាគីនឹងទាក់ទាញឲ្យមានហត្ថលេខីគ្រប់គ្រាន់ ឬឲ្យមានហត្ថលេខីត្រឹមត្រូវ ដើម្បីធ្វើឲ្យមានខុសប្លែកសម្រាប់ប្រទេសជាភាគីឆ្លើយតបការពារខ្លួនពីបណ្តឹងទាមទារបាន។

ទោះជាយ៉ាងណាក៏ដោយ ស្ទើរគ្រប់ផ្នែក កិច្ចខិតខំប្រឹងប្រែងនៃកំណែទម្រង់ទាំងអស់បានផ្តោតការយកចិត្តទុកដាក់លើការផ្លាស់ប្តូរយន្តការដោះស្រាយវិវាទរវាងវិនិយោគិននិងរដ្ឋ បានតិចតួច ហើយមិនបានពិចារណាច្រើនលើកំណែទម្រង់ជាមូលដ្ឋាន ដើម្បីផ្លាស់ប្តូរលើប្រព័ន្ធសន្ធិសញ្ញាវិនិយោគអន្តរជាតិ/ការដោះស្រាយវិវាទរវាងវិនិយោគិននិងរដ្ឋ ដែលត្រូវបានគេចាត់ថាមិនមានប្រសិទ្ធភាព ដោយខ្វះបទដ្ឋានគតិយុត្ត, មិនមានចេតនា និងមិនមានបំណងប្រើអភ័យឯកសិទ្ធិនៃបទដ្ឋានគតិយុត្តឡើយ។

មជ្ឈមណ្ឌលកូឡុំប៊ីស្តីពីការវិនិយោគប្រកបដោយនិរន្តរភាព យើងស្នើថា វាមានសារសំខាន់ក្នុងការវាយតម្លៃយ៉ាងទូលំទូលាយបន្ថែមទៀតលើការចំណាយ និងអត្ថប្រយោជន៍នៃសន្ធិសញ្ញាវិនិយោគ និងយន្តការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ និងពិចារណាឡើងវិញអំពីតួនាទីនៃកិច្ចព្រមព្រៀងវិនិយោគអន្តរជាតិ ថាវាពិតជាឧបករណ៍ជំរុញការអភិវឌ្ឍប្រកបដោយចិរភាព ដែលចេញពីទស្សនៈរបស់ប្រទេសកំណើត និងប្រទេសម្ចាស់ផ្ទះ។ នេះមានន័យថាយើងត្រូវមើលឲ្យបានស៊ីជម្រៅបន្ថែមទៀតលើ គោលដៅទាំងឡាយ នៃកិច្ចព្រមព្រៀងទាំងនេះ ហើយថា តើសន្ធិសញ្ញាវិនិយោគអន្តរជាតិអាចស្របគ្នាប្រសើរឡើងបានយ៉ាងដូចម្តេចខ្លះ ជាមួយនឹងគោលដៅអភិវឌ្ឍប្រកបដោយចិរភាព ក៏ផងដែរ ជម្រើសរបៀបដោះស្រាយវិវាទដែលអាចសម្រេចនូវគោលដៅបានប្រសើរជាងមុន។




ខណៈដែលកំពុងមានការពិភាក្សាលើកំណែទម្រង់នានា វិនិយោគិននៅតែបន្តដាក់បណ្តឹងទាមទារសំណង ហើយរដ្ឋក៏នឹងបន្តការពារខ្លួននៅក្នុងប្រព័ន្ធដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ ដែលបច្ចុប្បន្នត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថាក្តីបារម្ភដែលគេដឹង និងចេញពីការអនុវត្តជាក់ស្តែង ដែលនឹងទៅជាការបញ្ជាក់តាមផ្លូវច្បាប់កាន់តែច្បាស់។ ដូច្នេះ មជ្ឈមណ្ឌលកូឡុំប៊ីស្តីពីការវិនិយោគកំពុងតែស្វែងរកមធ្យោបាយក្នុងរយៈពេលខ្លី ដើម្បីឲ្យរដ្ឋទាំងឡាយអាចចាកចេញ ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃសន្ធិសញ្ញា ជាង ៣៣០០ ដែលបានបញ្ចប់រហូតដល់បច្ចុប្បន្ន។ ជម្រើសមួយចម្បងក្នុងចំណោមជម្រើសទាំងនេះ គឺយើងបានស្វែងរកការគាំទ្រឲ្យមាន ការបញ្ចប់ (ឬដកការយល់ព្រមចូលរួមយន្តការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ ដើម្បីជាដំណោះស្រាយរយៈពេលខ្លីគួបផ្សំជាមួយនឹងគម្រោងរយៈពេលវែង។



ccsi.columbia.edu

មជ្ឈមណ្ឌលកូឡុំប៊ីស្តីពី
ការវិនិយោគប្រកបដោយនិរន្តរភាព
Jerome Greene Hall
435 West 116th Street
New York, NY 10027
Phone: +1 (212) 854-1830

សូមសរសេរឯកសារយោងជា៖
មជ្ឈមណ្ឌលកូឡុំប៊ីស្តីពីការវិនិយោគប្រកបដោយនិរន្តរភាព, សេចក្តីសង្ខេបស្តីពី
សន្ធិសញ្ញាវិនិយោគអន្តរជាតិ និងការដោះស្រាយវិវាទរវាងវិនិយោគិន និងរដ្ឋ, ខែធ្នូ ឆ្នាំ ២០២១

បោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលកូឡុំប៊ីស្តីពីការវិនិយោគប្រកបដោយនិរន្តរភាព ដែលជា
មជ្ឈមណ្ឌលស្រាវជ្រាវអនុវត្តឈានមុខ និងជាវេទិកាសម្រាប់ការសិក្សាស្រាវជ្រាវ, ពិភាក្សា, និង
ការអនុវត្តការវិនិយោគជាអន្តរជាតិប្រកបដោយនិរន្តរភាព។